# របាយការណ៍
# ស្តីពី
# សកម្មភាពការងារប្រចាំខែមីនា ឆ្នាំ២០១០
# របស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
# និងទិសដៅសម្រាប់អនុវត្តបន្ត

ក្នុង ខែមីនា ឆ្នាំ២០១០ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធមិដោយមានអគ្គលេខាធិការដ្ឋានជាអង្គភាពប្រតិបត្តិ បានដំណើរការការងាររបស់ខ្លួនស្របតាមបេសកកម្មដែលបានកំណត់ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ហើយសម្រេចបាននូវលទ្ធផលជាក់ស្តែងដូចខាងក្រោម :

## ១_ការងារកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

### ក. ការងាររដ្ឋបាល

-ផ្ញើលិខិតលេខ ០១២/១០ លស.កកចយ ចុះថ្ងៃទី០១ខែមីនា ឆ្នាំ២០១០ ជូនឯកឧត្តមទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធាននាយកដ្ឋានបុគ្គលិក សំណើសុំបញ្ជូនមន្ត្រីរបស់ **កកចយ** មួយរូបចូលរៀនវគ្គវិក្រឹត្យការមន្ត្រីជន់ខ្ពស់ សម្រាប់ឆ្នាំ២០១០

-ផ្ញើលិខិតលេខ ០១៣/១០ លស.កកចយ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១០ ជូនឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សំណើសុំអនុញ្ញាតិបញ្ជូនមន្ត្រី ០១ រូប ទៅចូលរៀនវគ្គបណ្តុះបណ្តាលស្តីពីធន់ធានសេនេទិច និងកម្មសិទ្ធិបញ្ញានៅទីក្រុង Alnarp ប្រទេសស៊ុយអែត

-ផ្ញើលិខិតលេខ ០១៤/១០ លស.កកចយ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១០ ជូនឯកឧត្តម រដ្ឋមន្ត្រីក្រសួងយុត្តិធមិ សំណើសុំសៀវភៅក្រមព្រហ្មទណ្ឌចំនួន ៥០

-ទទួលលិខិតលេខ ៨២លអជ.រប ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១០ អញ្ជើញចូលរួមក្នុងអង្គប្រជុំអន្តរក្រសួងដើម្បីពិភាក្សាលើសេចក្តីព្រាងព្រះរាជក្រឹត្យ ស្តីពីច្បាប់ឈប់ និងច្បាប់ឈប់សម្រាករបស់មន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជាដែលនឹងប្រព្រឹត្តទៅនៅថ្ងៃព្រហស្បតិ៍ ទី០៤ ខែមីនា ឆ្នាំ២០១០

-ទទួលលិខិតលេខ ៩១ លអជ.រប ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១០ ចូលរួមក្នុងអង្គប្រជុំអន្តរក្រសួង ដើម្បីពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការកំណត់ឋានៈបណ្ឌិតសភាចារ្យរបស់ សាស្ត្រាចារ្យក្នុងវិស័យសុខាភិបាល ដែលប្រព្រឹត្តទៅនៅថ្ងៃពុធទី១០ ខែមីនា ឆ្នាំ២០១០

-ទទួលលិខិតលេខ ៩៤ លអជ.រប ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១០ ចូលរួមក្នុងអង្គប្រជុំអន្តរក្រសួង ដើម្បីពិភាក្សាលើការជំរុញការផ្សព្វផ្សាយ និងអនុវត្តន៍ឱ្យមានប្រសិទ្ធិភាពលើៈ១-សារាចរណែនាំលេខៈ១៣ សរណន របស់រាជរដ្ឋាភិបាល ចុះថ្ងៃទី២៨-១២-ឆ្នាំ២០០០ ២-សេចក្តីជូនដំណឹងលេខៈ១៣០៥ សជណ ចុះថ្ងៃទី០៧-០៩-២០០៧ ៣-សេចក្តីជូនដំណឹងលេខៈ១៩៥ សជណ.អគ ចុះថ្ងៃទី២៥-១០-២០០៧ ៤-សេចក្តីជូនដំណឹងលេខៈ៨២៧ សជណ.អគ ចុះថ្ងៃទី១៧-០៦-២០០៩ ៥-លិខិតស្នើលេខៈ២០៦៨ អ.គ ចុះថ្ងៃទី ២៤-១២-២០០៩ និងទី៦-លិខិតស្នើលេខៈ២២ លសកបរ ចុះថ្ងៃទី០២-០១-២០១០ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃព្រហស្បតិ៍ទី១១ ខែមីនា ឆ្នាំ២០១០

-ទទួលលិខិត ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ២០១០ ពីគម្រោងសិទ្ធិទទួលបានយុត្តិធម៌នៅកម្ពុជា ស្តីពីការអញ្ជើញឯកឧត្តមអគ្គលេខាធិការនៃ កកចយ ដើម្បីចូលរួមជាអធិបតីក្នុងពិធីសម្ពោធន៍" សៀវភៅណែនាំការសម្រុះសម្រួល និងសៀវភៅណែនាំប្រតិបត្តិការសម្រាប់មណ្ឌលសេវាកម្មយុត្តិធម៌ស្រុក និងគណៈកម្មាធិការដោះស្រាយទំនាស់ ឃុំ សង្កាត់" នៅសណ្ឋាគារ **សាន់វ៉េ** រាជធានីភ្នំពេញ

-ទទួលលិខិតលេខ ១៣៨ ជ.ច.ក/១០ ពីអង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា សំណើសុំអញ្ជើញ ឯកឧត្តមអគ្គលេខធិការចូលរួមក្នុងអង្គសិក្ខាសាលា ស្តីពីសិទ្ធិទទួលបានការលែងលះរបស់ស្ត្រីនៅកម្ពុជា

-ទទួលលិខិត ៩៧ លអជ.រប ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១០ អញ្ជើញចូលរួមជាកិត្តិយស ក្នុងពិធីបិទវគ្គប្រគល់វិញ្ញាបនបត្រសម្បទាខាងវិជ្ជាជីវៈមេធាវី ដល់សិស្សមេធាវីជំនាន់ទី៩ និងបើកវគ្គបណ្តុះបណ្តាលសិស្សមេធាវីជំនាន់ទី១០ ឆ្នាំសិក្សា២០០៩-២០១០ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១០ នៅសាលាភូមិន្ទរដ្ឋបាល

-ទទួលលិខិត ១០៤ លអជ.រប ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១០ ចូលរួមក្នុងអង្គប្រជុំអន្តរក្រសួង ដើម្បីពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការបង្កើតសញ្ញារបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១០

-ទទួលលិខិត ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១០ ពីគម្រោងសិទ្ធិទទួលបានយុត្តិធម៌ ស្តីពីសំណើគោរពអញ្ជើញឯកឧត្តមអគ្គលេខាធិការ ចូលរួមសិក្ខាសាលា ស្តីពី"ការសម្ពោធឯកសារចងក្រងវិធានប្រពៃណីជនជាតិដើមភាគតិចដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១០ នៅសណ្ឋាគាកាំបូឌីយ៉ាណា

-ទទួលលិខិតលេខ ១១៣ លអជ.រប ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១០ អញ្ជើញចូលរួម ក្នុងពិធីចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នា ស្តីពីៈ ១- ការពង្រឹងកិច្ចសហប្រតិបត្តិការកសិកម្ម រវាងក្រសួងកសិកម្មចិន និងក្រសួងកសិកម្មរុក្ខាប្រម៉ាញ់ និងនេសាទ នៃកម្ពុជា ២- ការបង្កើតភាពជាដៃគូយុទ្ធសាស្ត្រ រវាងក្រសួងប្រៃសណីយ៍ និងទូរគមាគមន៍ និងក្រុមហ៊ុន (HUAWEI TECHNOLOGIES) ៣-កិច្ចព្រមព្រៀងសម្រាប់បរិក្ខាទូរគមនាគមន៍

និងការផ្គត់ផ្គង់សេវា រវាងក្រុមហ៊ុន (CAMGSM)និងក្រុមហ៊ុន( HUAWEI TECHNOLOGIES ) ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១០ នៅទីស្តីការគណៈរដ្ឋមន្ត្រី

-ទទួលលិខិតលេខ ១២៦/១០ មពសក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១០ ស្តីពីការអនុញ្ញាតអញ្ជើញមន្ត្រីជំនាញមួយរូប ចូលរួមជាវាគ្មិនកិត្តិយស ក្នុងកម្មវិធីជជែកពិភាក្សាតុមូល ក្រោមប្រធានបទ **តុលាការគំរូ** នៅវិទ្យុ (FM102)មណ្ឌលព័តិមានស្ត្រីកម្ពុជា នៅថ្ងៃព្រហស្បតិ៍ទី២៩ ខែមេសា ឆ្នាំ២០១០

-ទទួលលិខិតលេខ ១១១ លអជ.រប ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១០ ចូលរួមជាកិត្តិយសក្នុងពិធីប្រកាសបើកកិច្ចប្រតិបត្តិការជំរឿនមន្ត្រីរាជការស៊ីវិល ទូទាំងប្រទេស ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម សុខ អាន ឧបនាយករដ្ឋន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០១០ នៅទីស្តីការគណៈរដ្ឋមន្ត្រី

-ទទួលលិខិតលេខ ១១២ លអជ.រប ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១០ ចូលរួមក្នុងអង្គប្រជុំអន្តរក្រសួង ដើម្បីពិភាក្សាលើសេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី ១៩ ខែមីនា ឆ្នាំ២០១០

-ទទួលលិខិតលេខ ១២១ លអជ.រប ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១០ ចូលរួមស្តាប់បទឧទ្ទេសនាម របស់ ឯកឧត្តម នាយឧត្តមសេនីយ៍ ជា តារា អគ្គមេបញ្ជាការរងកងយុទ្ធពលខេមរភូមិន្ទ និងជាគណៈបញ្ជាការឯកភាពទិសយោធភូមិភាគទី៤ ស្តីពីសភាពការណ៍នៅតំបន់ប្រាសាទព្រះវិហារ និងសភាពការណ៍ព្រំដែនកម្ពុជា-ថៃ ចាប់តាំងពីកើតព្រឹត្តិការណ៍រហូតដល់បច្ចុប្បន្ន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីដែលប្រព្រឹត្តទៅនៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១០នៅទីស្តីការគណៈរដ្ឋមន្ត្រី។

-ទទួលលិខិតលេខ ៥៧៣ ខន/០១០ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១០ ពីខុទ្ទការល័យ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី ស្តីពីការរៀបចំជូនមន្ត្រីរាជការ នឹងថ្នាក់ដឹកនាំ គ្រឹះស្ថានឧត្តមសិក្សាសាធារណៈ និងឯកជនបានស្តាប់បទឧទ្ទេសនាមរបស់ ឯកឧត្តម នាយឧត្តមសេនីយ៍ ជា តារា អំពីសភាពការណ៍នៅព្រំដែន

-ទទួលលិខិតលេខ១២៤ លអជ.រប ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១០ ចូលរួមក្នុងអង្គប្រជុំអន្តរក្រសួង ដើម្បីពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការកំណត់វិវាទជាតិលើកកំពស់អនាម័យជនបទ ដែលប្រព្រឹត្តទៅនៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១០

-ទទួលលិខិតលេខ ១២៥ លអជ.រប ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១០ អញ្ជើញចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពងខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោមៈ១-សេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ និង២-បញ្ហាផ្សេងៗ ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១០

-ទទួលលិខិតលេខ ៣៥៣/១០ ក.អ.ក/គជនា ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១០ ពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ស្តីពីកិច្ចប្រជុំលើកទី ១៦ នៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍

-បានទទួលលិខិត ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១០ ពីគម្រោងសិទ្ធិទទួលបានយុត្តិធម៌ ស្តីពីការចូលរួម ជាគណៈអធិបតីនៃអង្គសិក្ខាសាលាស្តីពីការ  បង្ហាញសមិទ្ធិផលនៃការអនុវត្តកម្មវិធីពង្រឹងសមត្ថភាពកិច្ចសន្ទនាសហគមន៍ និងផ្សព្វផ្សាយសៀវភៅស្តីពីការសន្ទនាអំពីអំពើហិង្សាក្នុងគ្រួសារ

-ទទួលលិខិតលេខ ១២០ លអជ.រប ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២១០ ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធសមិទ្ធិផលថ្មី នៅមណ្ឌមណ្ឌលសុខភាព ឃុំព្រៃកប្បាស់ ស្រុកព្រៃកប្បាស់ ខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដែលប្រព្រឹត្តទៅនៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០១០ នៅឃុំព្រៃកប្បាស់ ស្រុកព្រៃកប្បាស់ ខេត្តតាកែវ

-ទទួលលិខិតលេខ ៣៩២ សជណ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១០ ស្តីពីការលើថ្ងៃក្នុងពិធីសម្ពោធសមិទ្ធិផលថ្មីនៅមណ្ឌលសុខភាព ឃុំព្រៃកប្បាស ស្រុកព្រៃកប្បាស ខេត្តតាកែវ ត្រូវលើកទៅថ្ងៃទី០៥ ខែមេសាឆ្នាំ២០១០ វិញ ឯពេលវេលា និងទីកន្លែងរក្សានៅដដែល

-ទទួលលិខិតលេខ ៣៦០/១០ កអក/គជនា ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១០ ពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ស្តីពីការអញ្ជើញចូលរួម ក្នុង វេទិការសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី៣ នាថ្ងៃទី២-៣ ខែមិថុនា ឆាំ២០១០ នៅវិមានរដ្ឋាភិបាល

-ទទួលលិខិតលេខ ១២៦ លអជ.រប ចុះថ្ងៃទី២៥  ខែមីនា ឆ្នាំ២០១០ ចូលរួមក្នុងអង្គប្រជុំអន្តរក្រសួង ដើម្បីពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការអនុវត្តន៍ច្បាប់ជីវសុវត្ថភាព ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី៣០-៣១ ខែមីនា ឆ្នាំ២០១០

-ទទួលលិខិតលេខ១២៨ លអជ.រប ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១០ ចូលរួមក្នុងអង្គប្រជុំអន្តរក្រសួង ដើម្បីពិភាក្សាលើសេចក្តីព្រាងកម្មវិធីព្រៃឈើជាតិ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី០១-០២ ខែមេសា ឆ្នាំ២០១០

-ទទួលលិខិតលេខ ៣៦៥/១០ កអក/គជនា ចុះថ្ងៃទី២៦ ខែមីនាឆ្នាំ២០១០ ពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ស្តីពី ការអញ្ជើញចូលរួមក្នុងអង្គវិបស្សនាសម្រាប់ក្រុមការងារបច្ចេកទេសចម្រុះរយៈពេលពីថ្ងៃ ( ថ្ងៃទី៨-០៩ ខែមេសា ឆ្នាំ២០១០ ) នៅខេត្តសៀមរាប

-ទទួលលិខិតលេខ ១៣៤ លអជ.រប ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១០ ស្តីពីការអញ្ជើញចូលរួម ក្នុងអង្គសិក្ខាសលា ស្តីពីកិច្ចប្រតិបត្តិការជំរឿនមន្ត្រីរាជការស៊ីវិលទូទាំងប្រទេស ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី០២ ខែមេសា ឆ្នាំ២០១០ វេលាម៉ោង ០៨:៣០ នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី

-ទទួលលិខិតលេខ ៣៦០ សជណ.បល  ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១០ ស្តីពីការចាត់តាំងមន្ត្រី ចូលរួមវគ្គបណ្តុះបណ្តាលបន្តសម្រាប់ឆ្នាំ២០១០ នៅសាលាភូមិន្ទរដ្ឋបាល

**ខ. ការងារកំណែទម្រង់**

-រៀបចំកិច្ចប្រជុំស្តីពីការបញ្ចប់របាយការណ៍លើសំណើក្របខ័ណ្ឌនៃការអនុវត្តប្រព័ន្ធអំបុដ្ស្មាន់នៅកម្ពុជា កាលពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០១០ នៅសណ្ឋាគារអាំងទែកុងទីណង់តាល់

-រៀបចំកិច្ចប្រជុំកិច្ចប្រជុំពិភាក្សាទៅលើការធ្វើបច្ចុប្បន្នកម្មផែនការសកម្មភាពទាំង ៩៧ នៃកម្មវិធីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ នៅសណ្ឋាគារអាំងទែកុងទីណង់តាល់ កាលពីថ្ងៃទី០២ ខែមីនា ឆ្នាំ២០១០

-បានចុះទៅសិក្ខាសាលានៅខេត្តព្រះសីហនុ រយៈពេលពីរថ្ងៃ ដើម្បីបន្តការធ្វើផែនការយុទ្ធសាស្ត្ររយៈពេលប្រាំឆ្នាំ (២០០៩-២០១៣) និងផែនការការងាររបស់អគ្គលេខាធិការ ដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ កាលពីថ្ងៃទី០៣-០៥ ខែមីនា ឆ្នាំ២០១០

-បានរៀបចំកិច្ចប្រជុំផ្ទៃក្នុងរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ក្រោមអធិបតីភាពរបស់ឯកឧត្តម សួង លាងហៃ អគ្គលេខាធិការរង ជាមួយដៃគូរអភិវឌ្ឍន៍ ដើម្បីបន្តពិភាក្សាទៅលើការធ្វើផែនការយុទ្ធសាស្ត្រ និងបញ្ចប់ការធ្វើផែនការការងាររបស់អគ្គលេខាធិការដ្ឋាន

-បានរៀបចំកិច្ចប្រជុំពិភាក្សាស្តីពីការរៀបចំសៀវភៅកម្រងព័ត៌មានសេវាសាធារណៈពាក់ព័ន្ធនឹងវិស័យយុត្តិធម៌ និងអាជ្ញាកណ្តាល ក្រោមអធិបតីភាព ឯកឧត្តម ស៊ុយ ម៉ុងលាង អគ្គលេខាធិការ នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដែលប្រព្រឹត្តទៅនៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១០

**គ. ផ្សេងៗ**

-ចូលរួមប្រជុំអន្តរក្រសួង

-ចូលរួមធ្វើជាវាគ្មិនកិត្តិយសក្នុងសម្ភាសន៍របស់វិទ្យុអាស៊ីសេរី ទៅលើប្រធានបទៈ កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ កាលពីយប់ថ្ងៃទី០១ ខែមីនា ឆ្នាំ២០១០

-ចូលរួមក្នុងអង្គប្រជុំពេញអង្គ គណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោមៈ១-សេចក្តីព្រាងផែនការ យុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ និង២-បញ្ហាផ្សេងៗ ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១០

-ចូលរួមជាអធិបតីក្នុងពិធីសម្ពោធន៍ "សៀវភៅណែនាំពីការសម្រុះសម្រួល និងសៀវភៅណែនាំប្រតិបត្តិការសម្រាប់មណ្ឌលសេវាកម្មយុត្តិធម៌ស្រុក និងគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់" ដែលរៀបចំដោយស្រួងយុត្តិធម៌ និងក្រសួងមហាផ្ទៃ នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១០ នៅសណ្ឋាគា សាន់វ៉េ ភ្នំពេញ។

-ចូលរួមសិក្ខាសាលា ស្តីពី"ការធីសម្ពោធឯកាសារចងក្រងវិធានប្រពៃណីជនជាតិដើមភាគតិច" ដែលរៀបចំដោយគម្រោងសិទ្ធិទទួលបានយុត្តិធម៌ ដែលប្រព្រឹត្តទៅនៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១០ នៅសណ្ឋាគារកាំបូឌី យ៉ាណា រាជធានីភ្នំពេញ។

-ចូលរួមសិក្ខាសាលាស្តីពីការបង្ហាញសមិទ្ធផលនៃការអនុវត្តកម្មវិធី"ពង្រឹងសមត្ថភាព សន្ទនាសហគមន៍ នាថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១០ នៅសណ្ឋាគារ អ៊ីមភីរៀ

**២-សន្និដ្ឋាន**

ក្នុងខែមីនា ឆ្នាំ២០១០ នេះក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយមានអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ជាអង្គភាពប្រតិបត្តិបានបំពេញការងាររបស់ខ្លួនទៅតាមការគ្រោងទុក ជាពិសេសបានប្រជុំពិនិត្យពិភាក្សាបញ្ចប់របាយការណ៍ស្ដីពីសំណើក្របខ័ណ្ឌនៃការអនុវត្តន៍ប្រព័ន្ធអំប៊ូស្មាន់នៅកម្ពុជា និងប្រជុំពិនិត្យមើលឡើងវិញនូវការអនុវត្តកម្មវិធីសកម្មភាពកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ព្រមទាំងបានធ្វើសិក្ខាសាលាបញ្ចប់ផែនការយុទ្ធសាស្ត្រ (២០០៩-២០១៣) និងផែនការការងាររបស់អគ្គលេខាធិការដ្ឋានទៀតផង។

**៣-ទិសដៅអនុវត្តក្នុងខែមេសា**

-បន្តប្រជុំរៀបចំផែនការ ការងារសម្រាប់ផ្នែកផ្សេងៗរបស់អគ្គលេខាធិការដ្ឋាន

-បន្តការងារបច្ចុប្បន្នកម្ម កម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការបច្ចុប្បន្នកម្ម ២០១០-២០១៣

-កែសម្រួលសេចក្ដីព្រាងសំណើក្របខ័ណ្ឌបញ្ចូលប្រព័ន្ធអំប៊ូស្មាន់នៅកម្ពុជា

*រាជធានីភ្នំពេញ, ថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១០*

**អ្នកធ្វើរបាយការណ៍**

ស៊ុន សិរីវុធ

**បានឃើញ និងឯកភាព**

**អគ្គលេខាធិការ**

**ស៊ុយ ម៉ុងលាង**